ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥ ០៨ ១២៤ ប្រ.ក

លិខិតចូល
ថ្ងៃទី២៧ ខែសីហា ឆ្នាំ2008

# ប្រ កា ស

## ស្តីពី

## ការបង្កើតគណៈកម្មការកំណត់អត្រាប្តូរប្រាក់

---

**ទេសាភិបាលធនាគារជាតិកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រប់គ្រងការប្តូរប្រាក់

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី

-តាមសំណើរបស់អគ្គនាយកដ្ឋាន

-យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## ស ម្រេ ច

**ប្រការ ១.-** បង្កើតគណៈកម្មការមួយឈ្មោះថា "គណៈកម្មការអត្រាប្តូរប្រាក់" ដើម្បីកំណត់ចេញនូវអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ដែលរួមមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១-អគ្គនាយក | ជាប្រធាន |
| ២- អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | ជាអនុប្រធាន |
| ៣-អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានប្រតិបត្តិការ | ជាអនុប្រធាន |
| ៤- ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | ជាសមាជិក |
| ៥- ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច | ជាសមាជិក |
| ៦- ប្រធាននាយកដ្ឋានប្រតិបត្តិការ | ជាសមាជិក |
| ៧- ប្រធាននាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា | ជាសមាជិក |

**ប្រការ ២.-** គណៈកម្មការអត្រាប្តូរប្រាក់មានភារកិច្ចដូចតទៅ :

- តាមដានស្ថានភាពសេដ្ឋកិច្ចរាចរូបិយវត្ថុ និងអត្រាប្តូរប្រាក់នៅលើទីផ្សារ និងតាមដានព័ត៌មានផ្សេងៗទៀត ដែលចាំបាច់ដើម្បីជាមូលដ្ឋានក្នុងការកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ។
- ចូលរួមប្រជុំរាល់ព្រឹកនៃថ្ងៃធ្វើការដើម្បីកំណត់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ
- រាយការណ៍ជូនទេសាភិបាលអំពីស្ថានភាពអត្រាប្តូរប្រាក់នៅលើទីផ្សារ ។

**ប្រការ ៣.-** ក្នុងករណីមានភារកិច្ចចាំបាច់ជាយថាហេតុ លោក-លោកស្រី ដែលជាសមាជិកគណៈកម្មការដូចមានចែងក្នុងប្រការ១ ខាងលើត្រូវទទួលខុសត្រូវរៀងៗខ្លួន ក្នុងការចាត់តំណាងដែលមានសមត្ថភាពក្តាប់បានអំពីស្ថានភាពសេដ្ឋកិច្ចរាចរូបិយវត្ថុ និងស្ថានភាពអត្រាប្តូរប្រាក់នៅលើទីផ្សារ ដើម្បីចូលរួមប្រជុំតាមការកំណត់របស់គណៈកម្មការ ។

**ប្រការ ៤.-** ប្រធានគណៈកម្មការអត្រាប្តូរប្រាក់ដោយផ្អែកតាមបញ្ជាទេសាភិបាល ត្រូវចុះហត្ថលេខាលើសេចក្តីជូនដំណឹងស្តីពីអត្រាប្តូរប្រាក់រៀងរាល់ថ្ងៃធ្វើការ ។

**ប្រការ ៥.-** ប្រកាសលេខ ធ៩.០០.១៦៨ ប្រក ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០០ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន - អង្គភាព ក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងសាមីជនត្រូវអនុវត្តនូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៧.-** ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០៨

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល:**

-ដូចប្រការ៦ "ដើម្បីអនុវត្ត"

-កាលប្បវត្តិ-ឯកសារ

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-សមាជិកក្រុមប្រឹក្សាភិបាល

"ដើម្បីជូនជ្រាប"

-នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"